អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

# អង្គភាពជនរងគ្រោះ

ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០

## អង្គភាពជនរងគ្រោះធ្វើការពន្យាពេលម៉ោងធ្វើការសម្រាប់ ការដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីចុងក្រោយក្នុងសំណុំរឿង០០២

អង្គភាពជនរងគ្រោះកំពុងធ្វើការពន្យាពេលម៉ោងធ្វើការរបស់ខ្លួន ក្នុងគោលបំណងជួយសម្រួលដល់បុគ្គលគ្រប់រូប ដែលប្រាថ្នាចង់ដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ដែលធ្វើការចោទប្រកាន់ប្រឆាំងនឹង អៀង សារី អៀង ធីរិទ្ធ នួន ជា ខៀវ សំផន និង កាំង ហ្គេកអ៊ាវ។

ខណៈដែលសហចៅក្រមស៊ើបអង្កេតជូនដំណឹងនៅថ្ងៃនេះអំពីការបញ្ចប់កិច្ចស៊ើបអង្កេត ដូច្នេះថ្ងៃផុតកំណត់នៃការទទួលពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីគឺ **ម៉ោង៧.០០ល្ងាច ថ្ងៃសុក្រ ទី២៩ ខែមករា ឆ្នាំ២០១០។ នេះជាថ្ងៃផុតកំណត់ចុងក្រោយ ហើយដែលមិនអាចពន្យាពេលទៀតបានឡើយ**។

ដើម្បីទទួលបាននូវឱកាសអតិបរិមាសម្រាប់បុគ្គលគ្រប់រូប ដែលប្រាថ្នាចង់ដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ឬសុំការពន្យល់បកស្រាយ ឬជំនួយផ្សេងៗ **ចាប់ពីថ្ងៃនេះតទៅ**ទល់នឹងថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ អង្គភាពជនរងគ្រោះនឹងដំណើរការតាមម៉ោងធ្វើការដូចខាងក្រោម៖

ថ្ងៃច័ន្ទ-ថ្ងៃសុក្រ: ម៉ោង **8:00** ព្រឹក - **7:00** ល្ងាច
ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ: ម៉ោង **8:00** ព្រឹក - **5:00** ល្ងាច

អង្គភាពជនរងគ្រោះមានទីតាំងនៅផ្ទះលេខ៦អា ផ្លូវ២១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ជារៀងរាល់ថ្ងៃ គឺចាប់ពីម៉ោង **8:00** ព្រឹក - **8:00** ល្ងាច លោក-អ្នកអាចទាក់ទងទូរស័ព្ទជំនួយរបស់អង្គភាពជនរងគ្រោះបាន តាមរយៈលេខ **012 842861, 097 7424218** ឬ **023 214 291**

អ៊ីម៉ែលអង្គភាពជនរងគ្រោះ: victimsunit@eccc.gov.kh